# អរិយធម៌អេហ្ស៊ីបបុរាណ

អរិយធម៌អេហ្ស៊ីបបុរាណមានអាយុកាលជាង ៣០០០ ឆ្នាំមុនគ.ស ដែលបានក្លាយជាអរិយធម៌ដំបូងមួយក្នុងចំណោមអរិយធម៌ក្នុងប្រវត្តិសាស្ត្រពិភពលោក។ អរិយធម៌អេហ្ស៊ីបបុរាណមានវិសាលភាពទឹកដីប៉ែកខាងជើងរហូតដល់ប្រទេស ស៊ីរី និងខាងត្បូងរហូតដល់ប្រទេសសូដង់ ប៉ុន្តែមុននឹងក្លាយជាអាណាចក្រមួយ អេហ្ស៊ីប គឺជារដ្ឋឯករាជ្យមួយដែលមានការរីកចម្រើននៅតាមបណ្តោយទន្លេនីល នៅខាងជើងនៃទ្វីបអាហ្វ្រិក។ ទីក្រុងនៃអាណាចក្រអេហ្ស៊ីបបុរាណត្រូវបានបែងចែកជាពីរ ទៅតាមខ្សែទឹកនៃទន្លេនីល ខ្សែទឹកខាងលើហៅថា អេហ្ស៊ីបលើ ឬអេហ្ស៊ីបខាងត្បូង និងខ្សែទឹកខាងក្រោមហៅថា អេហ្ស៊ីបក្រោម ឬអេហ្ស៊ីបខាងជើង (រូបលេខ១)[១]។ អរិយធម៌អេហ្ស៊ីបក៏មិនខុសអ្វីពី មេសូប៉ូតាមីនោះទេ ដោយសារជ្រើសរើសយកទីតាំងតំបន់ទន្លេនេះ គឺស្របទៅតាមវិស័យកសិកម្ម នេសាទ និងការចិញ្ចឹមសត្វដែលពឹងផ្អែកទៅលើប្រភពទឹក។

នៅក្នុងអរិយធម៌អេហ្ស៊ីបអ្នកស្រាវជ្រាវបានបែងចែកជា៣សម័យកាលធំៗគឺ អេហ្ស៊ីបសម័យបុរាណ អេហ្ស៊ីបសម័យកណ្តាល និងអេហ្ស៊ីបសម័យថ្មី។ អេហ្ស៊ីបបុរាណដឹកនាំដោយស្តេចដែលមានបរមនាមថា ផារ៉ាអុង។[២] នៅក្នុងប្រវត្តិសាស្ត្ររបស់អេហ្ស៊ីបស្តេចដែលមានបរមនាមនេះ មានប្រមាណជាង៣០០អង្គ ដែលបានបង្ហាញនៅក្នុងសិលាចារឹកផ្សេងៗ[៣]

ចំពោះពាក្យ ផារ៉ាអុង មានន័យថាផ្ទះធំនៅភាសាអេហ្ស៊ីប ហើយមិនយូរប៉ុន្មានពាក្យនេះក៏មានន័យថា ជាមេដឹកនាំបន្ទាប់ពីការប្រើប្រាស់នៅក្នុងគម្ពីរ ហេព្រើ (Hebrew)។[៤] នៅក្នុងគម្ពីរហេព្រើ ពាក្យនេះមានន័យថា ជាអ្នកការពារមនុស្សជាតិ និងជាអ្នកទំនាក់ទំនងរវាងព្រះ និងមនុស្ស។[៥] នៅពេលដែលស្តេចផារ៉ាអុងសុគត្គ គេនាំគ្នាកសាងប្រាសាទដែលជា

---

[១] Li Yan Sheng, 2015, p.5

[២] John Rearick , 2002, 2.

[៣] https://www.universalis.fr:le terme Pharaon

[៤] សូមមើល ៖ https://www.nationalgeographic.com: Tout comprendre sur : l'ancienne Égypte

[៥] John Rearick , 2002, 5.

អត្ថបទដោយ៖ អេង តុលា

ផ្នូររបស់ទ្រង់ ខុទា. ពីរ៉ាមីត ជីសា ។ ក្រៅពីនេះគេក៏កសាងទីកន្លែងបញ្ចុះសពក្រោមដីនៅជ្រលងភ្នំស្តេចដែលមានចំងាយ៦៥០គីឡូ ពីទីក្រុង Cairo បច្ចុប្បន្ន (រូបលេខ២)។ នៅជ្រលងភ្នំស្តេចជាទីកន្លែងបញ្ចុះសពរបស់ខ្សែរាជវង្ស ដែលទំនៀមនៃការបញ្ចុះនោះ គឺគេរុំសពដោយក្រណាត់ រួចដាក់ក្នុងមឈូសដែលហៅថា Mummy (រូបលេខ៣-៥)។ ការបញ្ចុះសព Mummy នោះ គឺពួកគេបានបញ្ចុះជាមួយវត្ថុសំណែនផ្សេងៗដូចជា មាស គ្រឿងអលង្ការ និងសត្វចិញ្ចឹមរបស់ពួកគេផងដែរ។[៦]

សព្វថ្ងៃសំណង់ផ្សេងៗដែលយើងឃើញដូចជា ប្រាសាទពីរ៉ាមីតជីសា ដែលជាកស្តុតាងនៃការគោរពប្រតិបត្តិរបស់សាសនាអេហ្ស៊ីបបុរាណ។ រាល់សំណង់ស្ថាបត្យកម្មទាំងនោះ វាបានបង្ហាញឱ្យយើងឃើញអំពី ការរីកចម្រើនផ្នែកវប្បធម៌ និងគំនិតនៃមនុស្សអេហ្ស៊ីបដែលទាក់ទងនឹងចំណេះដឹងខ្ពស់ ផ្នែកគណិតវិទ្យាក្នុងការគណនា ទម្ងន់ ប្លង់ និងលំហដើម្បីកសាងប្រាសាទពីរ៉ាមីត និងសំណង់សាសនាផ្សេងៗ។

ក្រៅពីនេះពួកគេបានបង្កើតអក្សររូបដែលមានអត្ថន័យ ដែលហៅថា Hieroglyphic (រូបលេខ៧)។ ប្រព័ន្ធនៃការប្រើប្រាស់អក្សររូបនេះ គឺមានអាយុកាលប្រមាណជាង៣០០០ឆ្នាំមុនគ.ស ដែលអក្សររូបនោះមានប្រមាណជាង ១០០០ តួទម្រង់[៧] ហើយវាត្រូវបានប្រើប្រាស់សម្រាប់ឆ្លាក់នៅលើប្រាសាទ មឈូស និងនៅលើវត្ថុទីសក្ការៈផ្សេងៗទៀត។ ក្រោយមកទៀតអក្សររូបនោះ បានធ្វើការវិវត្តន៍ក្លាយជាទម្រង់អក្សរថ្មីមួយផ្សេងទៀត ដែលហៅថា Hieratic ដែលដូចអក្សរមនុស្សសព្វថ្ងៃ ហើយអក្សរ Hieratic នោះ គឺសរសេរនៅលើក្រដាសដែលធ្វើអំពីស្មៅ ប៉ាពីរុស (Papyrus) ប៉ាពីរុស គឺជារុក្ខជាតិម្យ៉ាងដែលដុះនៅតាមតំបន់នៃទន្លេនីលនេះផ្ទាល់។[៨]

ភាពរីកចម្រើននៃអាណាចក្រអេហ្ស៊ីបបុរាណក៏ត្រូវបានធ្លាក់ចុះ ដោយការឈ្លានពានរបស់ចក្រភពពែកនៅឆ្នាំ ៩០០មុនគ.ស និងបញ្ចប់ដោយចក្រភពរ៉ូមាំងនៅឆ្នាំ ៣០ មុនគ.ស

---

[៦] https://www.nationalgeographic.com: ancient Egypt

[៧] https://www.britannica.com

[៨] https://www.worldhistory.org/Egyptian_Papyrus

អត្ថបទដោយ៖ អេង តុលា

អរិយធម៌អេហ្ស៊ីបបុរាណបានរីកចម្រើន និងលូតលាស់អស់រយៈពេលប្រមាណ៣០០០ឆ្នាំ[៩] ដែលបានបន្សល់ទុកនៅសំណង់ស្ថាបត្យកម្មបុរាណ រួមនឹងវត្ថុសិល្បៈជាច្រើនជាសម្បត្តិនៃមនុស្សជាតិ និងជាបេតិកភណ្ឌពិភពលោកសព្វថ្ងៃនេះ។ វត្ថុសិល្បៈមួយភាគធំបានដាក់តាំងបង្ហាញនៅសារមន្ទីរ Louvre នៃប្រទេសបារាំង។




រូបលេខ១៖ ផែនទីអេហ្ស៊ីបបុរាណ

ប្រភព៖ Printerest

៩ https://www.nationalgeographic.com: ancient Egypt

អត្ថបទដោយ៖ អេង តុលា



រូបលេខ២៖ ពីរ៉ាមីត ជីសា( Pyramid of Giza)
ប្រភព៖ World history



រូបលេខ៣៖ ជ្រលងភ្នំស្ដេច ដែលជាផ្នូររបស់ស្ដេចផ៉ារ៉ាអុង
ប្រភព៖ Linternaute.com

អត្ថបទដោយ៖ អេង តុលា



រូបលេខ២៤៖ ក្លោងទ្វារចូលនៃផ្នូរស្តេចRamses II
ប្រភព៖ Britannica.com



រូបលេខ២៥៖ មឈូស Mummy
តាំងបង្ហាញនៅសារមន្ទីរ វ៉ាទីកង់

អត្ថបទដោយ៖ អេង តុលា



រូបលេខ២៦៖ មឈូស mummy រួមជាមួយសំណែនផ្សេងៗ
តាំងបង្ហាញនៅសារមន្ទីរ វ៉ាទីកង់



រូបលេខ២៧៖ ផ្ទាំងសិលាចារិកអក្សរ Hieroglyphic ជាមួយនឹងរូបរបស់ស្ដេច
Pharaoh Mentuhotep II (ប្រភព៖ BBC)

អត្ថបទដោយ៖ អេង តុលា



រូបលេខ៨៖ ចម្លាក់អ្នកកត់ត្រា (script) តាំងបង្ហាញនៅសារមន្ទីរ ហ្លូវ( Louvre museum



រូបលេខ៩៖ របាំងមុខ តាំងបង្ហាញនៅសាមន្ទីរ វ៉ាទីកង់

អត្ថបទដោយ៖ អេង តុលា

# ឯកសារយោង

John Rearick
2002 Ancient Egypt

Li Yan Sheng
2015 World Civilisation

https://www.universalis.fr:le terme Pharaon

https://www.nationalgeographic.com /Ancient Egypt

https://www.britannica.com/Ancient Egypt

https://www.worldhistory.org/Egyptian_Papyrus

AMS
KHMER CIVILIZATION